**ស្ថានទូតអូស្ត្រាលី**
**រាជធានីភ្នំពេញ**

**សេចក្តីប្រកាសព័ត៌មាន**

## និស្សិតកម្ពុជាដែលបានទទួលអាហារូបករណ៍ដើម្បីទៅ សិក្សានៅប្រទេសអូស្ត្រាលីក្នុងឆ្នាំ ២០១២

នៅថ្ងៃទី ១៤ ធ្នូ ឆ្នាំ២០១១នេះ លោកជំទាវ **ផេននី រីឆាដស៍** ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំនៅកម្ពុជានឹងប្រារព្ធពិធីជប់លៀងជូនដំណើរនិស្សិតកម្ពុជា៣៣រូប ដែលបានប្រលងជាប់អាហារូបករណ៍អូស្ត្រាលីទៅសិក្សាថ្នាក់ក្រោយឧត្តមនៅប្រទេសអូស្ត្រាលី ។

និស្សិតកម្ពុជា៣៣នាក់ ដែលជាមន្ត្រីរាជការ សង្គមស៊ីវិល និង មកពីផ្នែកជំនួញនឹងទៅសិក្សាថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់និងថ្នាក់បណ្ឌិតនៅបណ្តាមហាវិទ្យាល័យនានាដែលមានកិត្យានុភាពនៅប្រទេសអូស្ត្រាលីនាឆ្នាំ២០១២ តាមរយៈការកម្មវិធីអាហារូបករណ៍លក្ខណៈពេញលេញរបស់រដ្ឋាភិបាលអូស្ត្រាលី។ ពួកគេនឹងទៅសិក្សានៅលើវិស័យចំបងនានាដូចជាសុខាភិបាល យ៉េនឌ័រ សេវាសង្គម កសិកម្ម ជលផល ការគ្រប់គ្រងបរិស្ថាន អភិវឌ្ឍន៍ជនបទ អភិវឌ្ឍន៍ទីក្រុង ប្រព័ន្ធច្បាប់និងយុត្តិធម៌ គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គ្រប់គ្រងព័ត៌មានវិទ្យា និង ហេដ្ឋារចនាសម្ព័ន្ធ ។

កម្មវិធីអាហារូបកឬណ៌អូស្ត្រាលីផ្តល់ឱកាសដល់ប្រជាជនមកពីប្រទេសកំពុងអភិវឌ្ឍន៍នៅជុំវិញពិភពលោកអោយទៅសិក្សានៅប្រទេសអូស្ត្រាលី។ អ្នកដែលទទួលបានអាហារូបករណ៍គឺជា អ្នកដែល មានសមទ្ធផលការងារខ្ពស់ និងមានសក្តានុពលអាចក្លាយជាអ្នកដឹកនាំ ដែលមានបំនងបង្កើននូវ ចំនេះដឹង ជំនាញ និងឯកទេសសំរាប់គាំទ្រដល់ការអភិវឌ្ឍន៍រយៈពេលវែងនៅក្នុងប្រទេសរបស់ពួកគេ ។

កម្មវិធីអាហារូបករណ៍អូស្ត្រាលី ពង្រឹងបន្ថែមនូវទំនាក់ទំនងជាវិជ្ជមានរវាងរដ្ឋាភិបាលទាំងពីរ និងប្រជាជននៃប្រទេសទាំងពីរ ។ ហើយទំនាក់ទំនងនេះក៏នឹងជួយបង្កើននូវទំនាក់ទំនងលើវិស័យធុរកិច្ច សិក្សាធិការ និងសង្គម ដែលនឹងជំរុញដល់ការអភិវឌ្ឍន៍ទាំងក្រុងស្រុក និងក្នុងតំបន់។

រដ្ឋាភិបាលអូស្ត្រាលី បានតាំងចិត្តក្នុងការជំរុញលើការសិក្សាជាន់ខ្ពស់និងការអភិវឌ្ឍន៍លើសមត្ថភាពប្រជាជននៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ ចាប់តាំងពីឆ្នាំ១៩៩៤មក មាននិស្សិតកម្ពុជាលើសពី៤៧០នាក់បានទទួលអាហារូបករណ៍សំរាប់ការអភិវឌ្ឍន៍រយៈពេលវែងដែលគាំទ្រដោយរដ្ឋាភិបាលអូស្ត្រាលី ។ ក្នុងចំនោមនោះមាននិស្សិតច្រើនជាង៣១០នាក់បានបញ្ចប់ការសិក្សាដោយជោគជ័យ ហើយត្រលប់មកកម្ពុជាវិញដោយមានជំនាញវិជ្ជាជីវៈខ្ពស់ជាងមុន ។ ពួកគេបានរួមចំណែកយ៉ាងសំខាន់សំរាប់ការសង្គមនិងសេដ្ឋកិច្ច

16B National Assembly Street, Sangkat Tonle Bassac Khan Chamkamon, Phnom Penh City, Kingdom of Cambodia
Telephone: 855 23 213470 Facsimile: 855 23 213413

កម្ពុជា ហើយមានភាគច្រើនក៏កំពុងតែកាន់តួនាទីជាន់ខ្ពស់នៅក្នុងរដ្ឋាភិបាល សង្គមស៊ីវិល និង ផ្នែកជំនួញ។ ក្នុងឆ្នាំ២០១១ មាននិស្សិតកម្ពុជាជាង៥០រូបបានប្រលងជាប់កម្មវិធីអាហារូបករណ៍ទៅសិក្សាថ្នាក់ក្រោយឧត្តមនៅប្រទេសអូស្ត្រាលី ។

ស្ថានទូតអូស្ត្រាលីមានមោទនភាពក្នុងការជប់លៀងជូនដំណើរដល់ក្រុមនិស្សិតកម្ពុជាដែលគួរអោយចាប់អារម្មណ៍និងមានភាពប្លែកៗពីគ្នានេះ នឹងសូមជូនពរអោយពួកគេធ្វើដំណើរប្រកបដោយជោគជ័យទាំងការសិក្សារនិង បទពិសោធន៏ផ្ទាល់ខ្លួននៅប្រទេសអូស្ត្រាលី ។

សំរាប់ពត៌មានបន្ថែមសំរាប់កម្មវិធីអាហារូបករណ៍អូស្ត្រាលី

www.australiaawards.gov.au

ទំនាក់ទំនងផ្នែកពត៌មាន៖ **លោក ដេវ ហ្គូច** លេខាធិការទីមួយ

ស្ថានទូតអូស្ត្រាលី រាជធានីភ្នំពេញ

email: dave.gordge@dfat.gov.au, phone: 023 213 470

១៣ ធ្នូ ២០១១